# តួនាទីវិនិយោគផ្ទាល់ពីបរទេស ក្នុងការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា[1]

## សេចក្តីផ្តើម

សេដ្ឋកិច្ចកម្ពុជាបន្តកើនឡើងយ៉ាងលឿន ចាប់តាំងពីបានបើកទ្វារទាក់ទងជាមួយសេដ្ឋកិច្ចសាកល នៅពាក់កណ្តាលទសវត្សរ៍ ១៩៩០ មក។ វិស័យកសិកម្មបន្តរួមចំណែកយ៉ាងច្រើនដល់ទៅ ៣៨% នៃ ផសស សរុប ពីឆ្នាំ ១៩៩៥ ដល់ ២០១០ ខណៈដែលវិស័យឧស្សាហកម្មរួមចំណែកបានជិតដល់ ២៣%។ ទោះបីមានកំណើនគួរឲ្យពេញចិត្តដល់ទៅ ១៦% ក្នុងរយៈពេល ១៨ឆ្នាំចុងក្រោយនេះក្តី ក៏ការអភិវឌ្ឍក្នុងវិស័យឧស្សាហកម្ម ត្រូវរាំងស្ទះខ្លះដោយសារចំណូល និងប្រាក់សន្សំក្នុងស្រុកមានកម្រិតទាប និងហេដ្ឋារចនាសម្ព័ន្ធនៅខ្វះខាត។ វិនិយោគផ្ទាល់ពីបរទេស (FDI) ដើរតួនាទីសំខាន់បំផុត ក្នុងការកៀងគរលំហូរមូលធនចូលមកក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងកំពុងមានកំហិតផ្នែកឥណទាន។ វាក៏នាំមកដែរនូវបច្ចេកវិទ្យាថ្មី ជួយជំរុញការអនុវត្តបែបថ្មី ជួយផ្ទេរចំណេះដឹងនិងជំនាញ និងកសាងសមត្ថភាពក្នុងស្រុក។ FDI ជះឥទ្ធិពលខ្លាំងណាស់ជួយលើកកម្ពស់អត្ថប្រយោជន៍ បានពីការធ្វើសមាហរណកម្មក្នុងតំបន់ និងក្នុងសហគមន៍អន្តរជាតិ (Olayiwola and Okodua n.d)។ លក្ខណៈសំខាន់មួយនៃ FDI គឺសមត្ថភាពជួយបង្កើនធនធានមនុស្ស និងបច្ចេកវិទ្យា ដែលជាកត្តាសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចរយៈពេលវែងក្នុងប្រទេសគោលដៅ។ FDI ចាំបាច់ណាស់ ប៉ុន្តែកត្តាតែមួយនេះមិនទាន់គ្រប់គ្រាន់សម្រាប់បង្កកំណើនសេដ្ឋកិច្ចទេ។ ឥទ្ធិពលមានខ្លាំងឬខ្សោយអាស្រ័យលើប្រភពនៃលំហូរ FDI វិស័យដែលបានទទួលវា ចំនួននៃធនធានមនុស្ស (ជំនាញ) ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងសមត្ថភាពស្រូបយករបស់ប្រទេសគោលដៅ។ បទពិសោធន៍សាកលបង្ហាញថា FDI មានដំណើរការល្អក្នុងប្រទេសមានចំណូលខ្ពស់ៗ និងប្រទេសមានគំលាតតូចផ្នែកបច្ចេកវិទ្យា។

អត្ថបទនេះផ្អែកលើលទ្ធផលនៃការសិក្សាមួយ (Phann 2013) ស្តីពី ការរួមចំណែកនៃលំហូរចូល FDI នៅក្នុងផលិតកម្មនៃឧស្សាហកម្មជ្រើសរើសចំនួន ៨ និងវិស័យឧស្សាហកម្មទាំងមូល។ ការសិក្សាបានប្រើ ទិន្នន័យម៉ាក្រូតាមពេលវេលាជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៩៧ ដល់ ២០១០ ដែលទទួលបានពី វិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (UNCTAD)។ មុខងារផលិតកម្ម (Production function) ត្រូវបានយកមកអនុវត្តផ្អែកលើម៉ូដែលកំណើន Solow (Barro and Sala-i-Martin 2004) ដែលគិតបញ្ចូលធាតុចូលតែ២គឺ ចំនួនមូលធន (K) និងពលកម្ម (L) ។ ដើម្បីបញ្ជាក់លើលទ្ធផល ការសិក្សាក៏បានពិនិត្យត្រួសៗពី បទពិសោធន៍នៅប្រទេសថៃ វៀតណាម ហ្វីលីពីន បង់ក្លាដេស និង មីយ៉ាន់ម៉ា ដែរ។

## វិស័យឧស្សាហកម្មកម្ពុជា

ដោយមានការជំរុញឡើងនៅដើមទសវត្សរ៍១៩៩០ ប្រទេសកម្ពុជាមានកំណើនក្នុងវិស័យឧស្សាហកម្មយ៉ាងខ្លាំង រហូតមកដល់ចុងឆ្នាំ២០០៨ ទើបធ្លាក់ចុះបន្តិចដោយសារវិបត្តិហិរញ្ញវត្ថុសាកល ហើយក្រោយមកក៏បានរើបឡើងវិញលឿនគួរសម ប៉ុន្តែមិនទាន់ដល់កម្រិតមុនពេលមានវិបត្តិទេ។ កំណើននេះកើតមានជាសំខាន់ពីវិស័យកាត់ដេរ ដែលជំរុញឡើងជាចម្បងដោយសារវិនិយោគបរទេស ជាពិសេសមកពីប្រទេសចិន។ នាពេលថ្មីៗ ក្នុងផ្នែកកម្មន្តសាលកម្មនៅតាមប្រទេសជឿនលឿន មានការបែកខ្ញែក ដោយសារអាជីវកម្មនានាបានផ្លាស់ប្តូរទីតាំងផលិតកម្មប្រើ

[1] អត្ថបទនេះរៀបរៀងដោយ ផាន់ ដាលីស អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១៖ ចំណែកនៃវិស័យឧស្សាហកម្មផ្សេងៗ នៅក្នុងផលិតកម្មឧស្សាហកម្មសរុប ឆ្នាំ២០០០-២០១០

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2000-2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | 42.1 | 48.7 | 50.4 | 52.6 | 56.3 | 54.5 | 55.5 | 56.3 | 55.3 | 51.4 | 58.1 | 53.2 |
| សំណង់ | 23.8 | 21.0 | 22.8 | 22.6 | 21.9 | 23.7 | 24.1 | 23.7 | 24.1 | 25.9 | 18.4 | 23.1 |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | 14.6 | 13.5 | 11.2 | 10.5 | 8.5 | 8.2 | 7.2 | 6.8 | 7.0 | 7.5 | 7.7 | 9.4 |
| កម្មន្តសាលកម្មផ្សេងទៀត | 10.0 | 9.0 | 8.4 | 8.1 | 7.5 | 7.8 | 7.6 | 7.5 | 7.7 | 8.5 | 8.6 | 8.3 |
| អគ្គិសនី ឧស្ម័ន និងទឹក | 1.9 | 2.0 | 1.9 | 1.8 | 1.7 | 1.7 | 1.9 | 2.0 | 2.1 | 2.3 | 2.4 | 2.0 |
| ឈើ ក្រដាស និងការបោះពុម្ពផ្សាយ | 4.3 | 2.7 | 2.3 | 1.8 | 1.6 | 1.6 | 1.4 | 1.4 | 1.4 | 1.5 | 1.5 | 2.0 |
| ការជីករ៉ែ | 1.1 | 1.1 | 1.2 | 1.2 | 1.3 | 1.5 | 1.4 | 1.4 | 1.6 | 2.0 | 2.4 | 1.5 |
| ផលិតផលធ្វើពីកៅស៊ូ | 2.2 | 2.0 | 1.7 | 1.4 | 1.1 | 0.9 | 0.8 | 0.8 | 0.8 | 0.9 | 1.0 | 1.2 |

ប្រភព៖ NIS (unpublished data 2000-2010)

តារាង២៖ តួលេខបូកបង្គរនៃការអនុម័តគម្រោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់របស់បរទេស ក្នុងវិស័យឧស្សាហកម្ម ដោយបែងចែកតាមអនុវិស័យ និងប្រទេសប្រភពវិនិយោគ ឆ្នាំ១៩៩៥-២០១០

| ប្រទេស ១៥ ចម្បងគេ (លានដុល្លារ) | វាយនភណ្ឌ សម្លៀកបំពាក់ និង ស្បែកជើង | ការជីករ៉ែ | ឈើ ក្រដាស និង ការបោះពុម្ពផ្សាយ | អាហារ ភេសជ្ជៈ និងថ្នាំជក់ | សំណង់ | ផលិតផល ធ្វើពីកៅស៊ូ | អគ្គិសនី ឧស្ម័ន និងទឹក | កម្មន្តសាលកម្ម ផ្សេងទៀត | 1995-2010 |
|---|---|---|---|---|---|---|---|---|---|
| ចិន | 450.5 | 574.5 | 84.0 | 130.0 | 6.1 | 196.1 | 1211.7 | 305.7 | 2958.6 |
| តៃវ៉ាន់ | 350.7 | 10.0 | 97.3 | 89.9 | 4.2 | | 50.0 | 65.0 | 667.1 |
| កូរ៉េ | 116.0 | 4.3 | 25.8 | 17.2 | 172.5 | 79.0 | 3.2 | 94.8 | 512.8 |
| ថៃ | 16.5 | 2.5 | 22.1 | 365.4 | 46.5 | | 25.4 | 18.0 | 496.4 |
| ម៉ាឡេស៊ី | 63.1 | | 236.2 | 27.6 | 2.7 | 31.7 | 64.8 | 59.0 | 485.1 |
| វៀតណាម | 1.6 | 0.4 | | 25.1 | 3.3 | 276.8 | 2.8 | 74.7 | 384.7 |
| សិង្ហបុរី | 57.2 | | 11.0 | 79.1 | 1.6 | 41.4 | 16.5 | 12.6 | 219.4 |
| ហុងកុង | 108.0 | | 62.5 | 10.1 | 4.3 | | | 25.3 | 210.2 |
| សហរដ្ឋអាមេរិក | 34.3 | 1.3 | 20.4 | 1.4 | | 28.5 | 8.7 | 53.4 | 148.0 |
| កាណាដា | 20.5 | 2.5 | | 4.3 | 39.5 | | | 13.7 | 80.5 |
| អង់គ្លេស | 68.4 | | 0.1 | 13.5 | | | | 2.3 | 84.3 |
| ឥណ្ឌា | | | | | | | 75.0 | 0.3 | 75.3 |
| ជប៉ុន | 7.1 | | | 31.5 | 2.8 | | | 15.2 | 56.6 |
| អូស្ត្រាលី | 12.9 | 4.3 | 5.3 | 15.8 | | | 0.3 | 2.3 | 40.9 |
| បែលហ្សិក | | | | | | | | 35.0 | 35.0 |
| សរុប | 1337.9 | 605.0 | 604.4 | 825.9 | 290.2 | 653.5 | 1459.3 | 794.6 | 6570.8 |

ប្រភព៖ CDC ( unpublished data 1995-2010 )

ពលកម្មច្រើន ទៅកាន់ប្រទេសមានតម្លៃពលកម្មថោកជាង ដើម្បីរក្សាលក្ខណៈប្រកួតប្រជែងរបស់ខ្លួន។ ព្រឹត្តិការណ៍នេះ ទំនងបើកផ្លូវមួយឲ្យកម្ពុជាបង្កើនគុណភាព និងធ្វើពិពិធកម្មរចនាសម្ព័ន្ធឧស្សាហកម្មរបស់ខ្លួន (Kimura 2009 cited in Banomyong 2010)។ វិស័យឧស្សាហកម្មកម្ពុជាបានល្អប្រសើរឡើងក៏ពិតមែន ប៉ុន្តែវាបានរីកលូតលាស់ដោយផ្អែកលើឧស្សហកម្មធុំដំឡើងដែលប្រើបច្ចេកទេសទាប និងប្រើពលកម្មច្រើន។ ឧស្សាហកម្មចម្បងៗនៅកម្ពុជា រួមមាន ការជីករ៉ែ, ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង, ឈើ ក្រដាស និងការបោះពុម្ពផ្សាយ, ផលិតផលធ្វើពីកៅស៊ូ, អគ្គិសនី ឧស្ម័ន និងទឹក, សំណង់ និងកម្មន្តសាលកម្មផ្សេងៗទៀត (តារាង១)។

## លំហូរចូល FDI ក្នុងឧស្សាហកម្មនៅកម្ពុជា

អត្រាសន្សំក្នុងប្រទេសកម្ពុជា មានកម្រិតទាប ត្រឹម ១៦% នៃ ផសស ពីឆ្នាំ២០០០ ដល់ ២០១០ ដែលបង្កនូវកង្វះទុនវិនិយោគក្នុងស្រុក និងតម្រូវការទាក់ទាញ FDI។ ក្រៅពីការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ, FDI ក៏នាំមកនូវទ្រព្យផលិតកម្មផ្សេងៗ និងចំណេះដឹងដែលអាចជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ នៅកម្ពុជា លំហូរចូល FDI តែងកំណត់ឡើងដោយកត្តាខាងក្រៅ (ដូចជា វិបត្តិក្នុងប្រទេសប្រភព FDI, លក្ខខណ្ឌអំណោយផលក្នុងទីផ្សារអន្តរជាតិ) ជាជាង កត្តាក្នុងស្រុក ដូចជា ពលកម្មថោក និងធនធានវត្ថុធាតុដើម ជាដើម។ ក្នុងឆ្នាំ២០១០ លំហូរចូល FDI មកក្នុងប្រទេសកម្ពុជា កើនដល់ ៥,៣% នៃ ផសស ធៀបនឹង ៣.៨% ក្នុងទសវត្សរ៍១៩៩០ និងត្រឹម ០,០២% ក្នុងទសវត្សរ៍១៩៧០ (UNCTAD)។ គិតជាមធ្យម ក្នុងឆ្នាំ២០០០-២០១០ វិស័យសេវាកម្មទទួលបានលំហូរចូល FDI ច្រើនបំផុត ដល់ទៅ ៥០% នៃ FDI សរុប ដែលបានអនុម័ត ហើយវិស័យឧស្សាហកម្មទទួលបាន ៤៩%។

រហូតមកទល់បច្ចុប្បន្ន ក្រៅពីសិទ្ធិពិសេសដែលផ្តល់ទៅឲ្យផ្នែកវាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង គឺនៅមិនទាន់មានកត្តាស្នូលអ្វីដែលចងភ្ជាប់វិនិយោគបរទេស ជាមួយនឹងសកម្មភាពឧស្សាហកម្មដទៃទៀតនៅកម្ពុជាឡើយ។ ទោះបីកម្ពុជាមានលក្ខណៈទាក់ទាញ ដោយសារសម្បុរកម្លាំងពលកម្មមានតម្លៃទាបក្តី ប៉ុន្តែ បន្ទុកចំណាយដ៏ខ្ពស់ក្នុងការបើកដំណើរការ និងធ្វើអាជីវកម្ម បានបន្ទុចបង្អាក់ដល់ FDI។ រូបភាព ១ ដែលប្រើសូចនាករនៃការធ្វើអាជីវកម្ម និងចងក្រងឡើងដោយធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បង្ហាញនូវចំណាត់ថ្នាក់ប្រទេសកម្ពុជា ក្នុងចំណោម ១៨៣ប្រទេស។

រូបភាព ១ ៖ ចំណាត់ថ្នាក់ការធ្វើអាជីវកម្មនៅកម្ពុជា ឆ្នាំ២០១២




ប្រភព៖ World Bank and IFC ( 2012 ), ការធ្វើអាជីវកម្ម

## ឥទ្ធិពល FDI នៅលើវិស័យឧស្សាហកម្ម: ក្របខ័ណ្ឌវិភាគផ្អែកលើបទពិសោធន៍ជាក់ស្តែង

ការសិក្សានេះ វិភាគពីការរួមចំណែកនៃ FDI ក្នុងការអភិវឌ្ឍឧស្សាហកម្ម ដោយប្រើជាមុខងារផលិតកម្ម Cobb-Douglas production function ( Barro and Sala-i-Martin 2004 ) ដែលបង្ហាញពីការប្រែប្រួលនៃផលិតផលសម្រេច ដោយសារមូលធន និងពលកម្ម ដែលដាក់ចូលទៅក្នុងដំណើរការផលិតកម្ម។ អ្នកស្រាវជ្រាវបានដាក់អនុវត្ត មុខងារផលិតកម្មខាងក្រោម សម្រាប់វិស័យឧស្សាហកម្មផ្សេងៗ សម្គាល់ឡើងដោយ i នៅកាល t ។

$$Y=F(K, L) \qquad (1)$$

where Y is real output of each industrial sector, K is physical capital and L is labour. K is defined by the sum of domestic capital stock ( $K_d$ ) and foreign capital stock ( $K_f$ ), which can be written as $K_{total}= K_d+ K_f$. The regression equation then assumes the following linear form:

$$logGDP_{it}=b_{oi}+b_{ii}logK_{dii(t-1)}+b_{2i}logK_{fi(t-1)}+b_{2i}logK_{fi(t-1)}+b_{3i}logL_{it}+u_{it} \qquad (2)$$

where $GDP_{it}$= the outputs of each industrial sector i at time t; $b_{0i}$, $b_{1i}$, $b_{2i}$ and $b_{3i}$ are the intercept terms and coefficients of each variable; $u_{it}$ is a term of residual of i sectors ( i=1, 2, 3... 9 representing the eight selected industrial sub-sectors and the overall industrial sector ); $K_{di}$ = DomK and $K_{fi}$ = FDIK which denote domestic and foreign capital stocks of industrial i.

To allow for delayed returns to capital outlay, as it may take enterprises some time to order and install capital assets such as machinery and equipment prior to operating, the study takes one lag of $K_{di}$ and $K_{fi}$ calculated using the perpetual inventory method. Then, $K_{(t+1)} = (1-d) * K_t + I_{(t+1)}$ where $K_{(t+1)}$ and $K_t$ are the capital stock in time ( t+1 ); t. d is the depreciation rate of capital, which is set at 5.0 percent for Cambodia ( see Net 2011 ); and $I_{t+1}$ is the fixed assets investment inflow at time ( t+1 ). The fixed assets investment shared by Cambodia is represented by $I_{d(t+1)}$, while the share of foreign nationality is written as $I_{f(t+1)}$. This study takes $K_{1995}$ as the initial capital stock for both domestic and foreign capital stocks for each selected industrial sector. Based on the assumption that the rate of capital-output ratio was constant during the 1990s, it then calculates $K_{1995} = I_{1995}/(g_{1990s}+d)$ following Harberger ( 1978 ), where $g_{1990s}$ is the average growth rate of capital, which is equal to the growth rate of outputs ( GDP ) during the 1990s, and $L_i$ is employment in sector i.

## លទ្ធផល

ការប៉ាន់ស្មានតាមសេដ្ឋកិច្ចមាត្រសាស្ត្របង្ហាញថា FDI មានផលល្អទៅលើឧស្សាហកម្មបួនវិស័យ គឺមាន អាហារ ភេសជ្ជៈ និងថ្នាំជក់, វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង, ទឹក និង

$$logGDP_food_t = b_{0food} + b_{1food}logDomK_food_{t-1} + b_{2food}logFDIK_food_{t-1} + b_{3food}logLabor_food_t + u_{foodt} \qquad (2.1)$$

$$logGDP_textiles_t = b_{0textiles} + b_{1textiles}logDomK_textiles_{t-1} + b_{2textiles}logFDIK_textiles_{t-1} + b_{3textiles}logLabor_textiles_t + u_{textilest} \qquad (2.2)$$

$$logGDP_rubber_t = b_{0rubber} + b_{1rubber}logDomK_rubber_{t-1} + b_{2rubber}logFDIK_rubber_{t-1} + b_{3rubber}logLabor_rubber_t + u_{rubbert} \qquad (2.3)$$

$$logGDP_mining_t = b_{0mining} + b_{1mining}logDomK_mining_{t-1} + b_{2mining}logFDIK_mining_{t-1} + b_{3mining}logLabor_mining_t + u_{miningt} \qquad (2.4)$$

$$logGDP_utility_t = b_{0utility} + b_{1utility}logDomK_utility_{t-1} + b_{2utility}logFDIK_utility_{t-1} + b_{3utility}logLabor_utility_t + u_{utilityt} \qquad (2.5)$$

$$logGDP_wood_t = b_{0wood} + b_{1wood}logDomK_wood_{t-1} + b_{2wood}logFDIK_wood_{t-1} + b_{3wood}logLabor_wood_t + u_{woodt} \qquad (2.6)$$

$$logGDP_construc_t = b_{0construc} + b_{1construc}logDomK_construc_{t-1} + b_{2construc}logFDIK_construc_{t-1} + b_{3construc}logLabor_construc_t + u_{construct} \qquad (2.7)$$

$$logGDP_othermanu_t = b_{0othermanu} + b_{1othermanu}logDomK_othermanu_{t-1} + b_{2othermanu}logFDIK_othermanu_{t-1} + b_{3othermanu}logLabor_othermanu_t + u_{othermanut} \qquad (2.8)$$

$$logGDP_indus_t = b_{0indus} + b_{1indus}logDomK_indus_{t-1} + b_{2indus}logFDIK_indus_{t-1} + b_{3indus}logLabor_indus_t + u_{indust} \qquad (2.9)$$

តារាង ៣: Ordinary Least Squares Results of Equation (2)

Dependent variable: LogGDP(t)_i
Method: Ordinary Least Squares
Sample: 1997, 2010
Included observations: 14

| | Constant | Coef. logDomK (t-1)_i | Coef. logFDIK (t-1)_i | Coef. logLabor(t)_i |
|---|---|---|---|---|
| (2.1) logGDP(t)_food | 4.415*** | -0.045 | 0.192*** | -0.023 |
| (2.2) logGDP(t)_textiles | 2.330** | -0.557 | 1.612** | -0.213 |
| (2.3) logGDP(t)_rubber | 3.113*** | -0.002 | 0.038 | -0.049 |
| (2.4) logGDP(t)_mining | -0.629 | 0.291 | 0.019 | 0.319*** |
| (2.5) logGDP(t)_utilities | 2.291*** | 0.164*** | 0.205** | -0.035 |
| (2.6) logGDP(t)_wood | 6.537*** | -0.330 | -0.014 | -0.194** |
| (2.7) logGDP(t)_construc | 0.253 | 0.594** | -0.345 | 0.330*** |
| (2.8) logGDP(t)_othermanu | 2.973*** | -0.079 | 0.493*** | -0.025 |
| (2.9) logGDP(t)_indus | 0.138 | 1.542** | -0.600 | 0.137 |

Note: * 10 percent, ** 5 percent and *** 1 percent level of significance. Source: Author's calculation.

អគ្គិសនី, និងកម្មន្តសាលកម្មផ្សេងទៀត។ ទោះយ៉ាងនេះក្ដី FDI កំពុងស្ថិតក្នុងដំណាក់កាល មានផលត្រឡប់ថយចុះជាលំដាប់ (តារាង ៣) ដែលបង្ហាញពីការប្រើប្រាស់មូលធនមិនមានប្រសិទ្ធភាព ហើយត្រូវការកែលំអផលិតភាព។ កម្ពុជានៅមិនទាន់ឈានឡើងដល់កម្រិតអាចយកចំណេញ បានពីសេដ្ឋកិច្ចមាត្រដ្ឋាននោះទេ។ ការសិក្សាមិនអាចបញ្ជាក់ពីឥទ្ធិពលនៃ FDI លើឧស្សាហកម្មទាំងមូលបាននោះទេ។ ឥទ្ធិពលខុសៗគ្នានៃ FDI ទៅលើវិស័យឧស្សាហកម្មខុសៗគ្នា អាចបណ្ដាលមកពីលក្ខណៈនៃ FDI ខ្លួនឯង, លក្ខណៈសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យជាក់លាក់នីមួយៗ, របាំងផ្សេងៗក្នុងបទបញ្ញត្តិច្បាប់, និងការិយាល័យធិបតេយ្យ (Lean, 2008)។ គេរកឃើញថា ម៉ូដែលទាំងអស់ហាក់ដូចជាប់ពាក់ព័ន្ធខ្លាំងទៅនឹងអថេរពេលវេលា គឺបានន័យថា ពេលវេលាមានផលប៉ះពាល់ ខ្លាំងជាង លក្ខណៈនៃទិន្នន័យ។ ដូច្នេះក្នុងរយៈពេលខ្លី ទិន្នន័យគុណភាពអន់និងមិនសូវច្បាស់លាស់ អាចធ្វើឲ្យលទ្ធផលរកឃើញមិនអាចប្រើការបាន ។

## បទពិសោធន៍បានពីប្រទេសជ្រើសរើសមួយចំនួនសម្រាប់កម្ពុជា

រចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា វាស្រដៀងគ្នានឹងនៅវៀតណាម បង់ក្លាដេស និង មីយ៉ាន់ម៉ា ដែរ។ វិស័យឈានមុខគេនៅតែជា វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង និងបន្ទាប់មកទៀត ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ដែលអំណោយផលល្អ ដោយសារមានកម្លាំងពលកម្មច្រើន និងតម្លៃទាប។ ផលិតកម្មវាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង ពឹងផ្អែកជាខ្លាំងលើការនាំចូល និងផ្គុំដំឡើង ធាតុចូលអន្តរការី (ផលិតផលពាក់កណ្ដាលសម្រេច) ដែលមានន័យថានៅពេលកាលៈទេសៈប្រែប្រួលអាក្រក់ ឬក៏ផុតកំណត់លក្ខខណ្ឌអនុគ្រោះ វិនិយោគក្នុងវិស័យនេះអាចរត់ចេញពីកម្ពុជាយ៉ាងលឿន។ ចំណុចផ្ដោតមួយក្នុងគោលនយោបាយរដ្ឋាភិបាល គឺការធ្វើពិពិធកម្មអនុវិស័យកែច្នៃម្ហូបអាហារ ដែលនៅក្មេងខ្ចីដោយសារមានផលិតផលតិចមុខ និងស្ដង់ដារគុណភាពអន់។

ដោយសារកម្ពុជា មិនទាន់មានលទ្ធភាពធ្វើវិនិយោគផ្នែកឧស្សាហកម្មធុនធ្ងន់ និងបច្ចេកវិទ្យាខ្ពស់ៗ ក្នុងពេលដ៏ខ្លីបាន ដូច្នេះត្រូវតែបន្តទ្រទ្រង់ឧស្សាហកម្មសព្វថ្ងៃ ដែលប្រើពលកម្មច្រើននេះ ហើយគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ក្នុងដំណាក់កាលបច្ចុប្បន្ន គួរលើកកម្ពស់ចំណងទាក់ទងគ្នាក្នុងកសិកម្ម និងផលិតកម្មប្រើពលកម្មច្រើន។ ចំណុចនេះសំខាន់ណាស់ ប្រសិនបើកម្ពុជាចង់សម្រេចបានសេដ្ឋកិច្ចមាត្រដ្ឋាន និងការអភិវឌ្ឍឧស្សាហកម្មប្រើបច្ចេកវិទ្យាខ្ពស់ ដែលនឹងជួយឲ្យកម្ពុជាអាចពង្រីកធនធានមនុស្ស មូលធនរូបវន្ត និងបង្កើនផលិតភាព ដើម្បីឲ្យដំណើរការឧស្សាហភាវូបនីយកម្មមានចីរភាព និងលក្ខណៈធន់ទ្រាំល្អ។ កម្ពុជាក៏ត្រូវរៀនជ្រើសរើសប្រភពវិនិយោគឲ្យបានល្អ ដើម្បីកសាងកម្លាំងប្រកួតប្រជែងរបស់ខ្លួន ជំរុញការអនុវត្តបែបថ្មី និងកាត់បន្ថយភាពក្រីក្រ។

## ការសន្និដ្ឋាន

លទ្ធផលសិក្សាតាមសេដ្ឋកិច្ចមាត្រសាស្ត្រ និងការវិភាគករណីសិក្សា បង្ហាញថា មានអនុវិស័យពីរដែលទំនងទាក់ទាញវិនិយោគខ្លាំង ពោលគឺ ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, ហើយនិងវាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង។ កម្ពុជាក៏ត្រូវរៀបចំខ្លួនដើម្បីទាក់ទាញគម្រោងវិនិយោគ មានប្រើបច្ចេកវិទ្យាខ្ពស់ៗ ដើម្បីអាចប្រកួតប្រជែងបានជាមួយគូប្រជែងថ្មីៗ ដូចជា មីយ៉ាន់ម៉ាជាដើម និងត្រៀមដោះស្រាយបញ្ហាថ្លៃឈ្នួលពលកម្មខ្ពស់ដែលអាចកើតមាននាពេលអនាគត។ក្នុងជំហានទី១កម្ពុជាគួរកំណត់នូវអនុវិស័យឧស្សាហកម្ម និងតំបន់ដ៏មានសក្ដានុពលនានា ហើយផ្ដល់អាទិភាពឲ្យ នៅក្នុងយុទ្ធសាស្ត្រគោលនយោបាយរបស់ខ្លួន។ ម្យ៉ាងទៀត កម្ពុជាក៏ត្រូវរៀនពីរបៀបបង្កើត និងគ្រប់គ្រងលក្ខខណ្ឌចាំបាច់ត្រូវមានជាមុននានា ដើម្បីពង្រឹងវិស័យផ្សេងៗដែលសម្រាប់ជួយទ្រទ្រង់ដល់ឧស្សាហកម្ម។ ជម្រើសគោលនយោបាយផ្សេងៗយ៉ាងត្រឹមត្រូវ ពិតជាសំខាន់បំផុតសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ជាពិសេសក្នុងពេលធនធានផលិតកម្មនៅមានតិចបែបនេះ៕

ឯកសារយោងមាននៅក្នុងអត្ថបទជាអង់គ្លេស